**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល ដែលសរសេរជាអក្សរកាត់ថា **គ.ស.ឌ.** ក្នុងគោលបំណងធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការបំពេញមុខងារដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គសង្គមទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព ឆ្លើយតបគ្រប់ផ្នែកទាំងបច្ចេកទេសនិងកម្លាំងពាក់ព័ន្ធនឹងការធានានិងការពារសន្តិសុខឌីជីថល។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.ស.ឌ.

**មាត្រា២ .-**

**គ.ស.ឌ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដែលរួមមាន សន្តិសុខសាយប័រ ឧក្រិដ្ឋកម្មសាយប័រ ការការពារជាតិក្នុងលំហសាយប័រ និងការទូតសាយប័រ
- ដឹកនាំសម្របសម្រួលកម្រិតនយោបាយ និងដាក់វិធានការក្នុងការឆ្លើយតបឧប្បត្តិហេតុសន្តិសុខសាយប័រសំខាន់ៗ និងការទប់ស្កាត់ហានិភ័យសន្តិសុខសាយប័រ ទាំងវិស័យសាធារណៈនិងវិស័យឯកជន
- ពិនិត្យនិងសម្រេចលើសំណើរៀបចំ កែសម្រួល និង/ឬធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- ជំរុញនិងពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- គ្រប់គ្រងនិងប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- សម្របសម្រួលនិងជំរុញកិច្ចសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុកសាងនិងអភិវឌ្ឍសន្តិសុខឌីជីថល
- ជំរុញ លើកទឹកចិត្ត និងគាំទ្រការកសាងនិងការអភិវឌ្ឍសន្តិសុខឌីជីថលពីគ្រប់មជ្ឈដ្ឋាន
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការចាំបាច់។

## ជំពូកទី៣
## សមាសភាពរបស់ គ.ស.ឌ.

**មាត្រា៣ .-**

**គ.ស.ឌ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - ឧបនាយករដ្ឋមន្ត្រី ១ រូប | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| - អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ស.ឌ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ស.ឌ.** អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិកដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ស.ឧ.

**មាត្រា៤ .-**

**គ.ស.ឧ.** ត្រូវប្រជុំរៀងរាល់ ៦ (ប្រាំមួយ) ខែម្ដង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានឬអនុប្រធានប្រចាំការ **គ.ស.ឧ.** អាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីដែលប្រធាន **គ.ស.ឧ.** អវត្តមាន ឬមានករណីចាំបាច់ ប្រធាន **គ.ស.ឧ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការ ឬអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **គ.ស.ឧ.** ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់តាំងថ្នាក់ដឹកនាំដែលមានសិទ្ធិសម្រេច ក្នុងនាមក្រសួង ស្ថាប័នខ្លួន ដើម្បីចូលរួមកិច្ចប្រជុំនិងសម្រេចជំនួស។

**មាត្រា៥ .-**

ប្រធាន **គ.ស.ឧ.** ឬអនុប្រធានប្រចាំការ ឬអនុប្រធានដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំ មានសិទ្ធិអញ្ជើញ ថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធ សមត្ថភាព និង ជំនាញវិជ្ជាជីវៈ ចូលរួមផ្ដល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.ស.ឧ.** តាមការចាំបាច់។

ក្នុងករណីដែលប្រធាន **គ.ស.ឧ.** មិនអាចបំពេញមុខនាទីដោយផ្ទាល់បាន ប្រធាន **គ.ស.ឧ.** អាច ចាត់តាំងអនុប្រធានប្រចាំការដឹកនាំការងារជំនួស។

**មាត្រា៦ .-**

**គ.ស.ឧ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- អង្គភាពសន្តិសុខសាយប័រកម្ពុជា
- អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ
- អង្គភាពការពារជាតិក្នុងលំហសាយប័រ
- អង្គភាពការទូតសាយប័រ
- លេខាធិការដ្ឋាន។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឧ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន **គ.ស.ឧ.** ដឹកនាំដោយអគ្គលេខាធិការដែលជារដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ទ.** និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដូចខាងក្រោម៖

- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពសន្តិសុខសាយប័រកម្ពុជា ដែលជាតំណាង **ក.ប.ទ.**
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ដែលជាតំណាងក្រសួង មហាផ្ទៃ
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពការពារជាតិក្នុងលំហសាយប័រ ដែលជាតំណាងក្រសួង ការពារជាតិ

- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពការទូតសាយប័រ ដែលជាតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកលេខាធិការដ្ឋាន ដែលជាតំណាង **ក.ប.ឌ.**
- អគ្គលេខាធិការរងមួយចំនួនទៀត តាមការចាំបាច់ ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ឌ.**។

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ដឹកនាំគ្រប់គ្រងការងារបច្ចេកទេសសន្តិសុខឌីជីថល និងជាសេនាធិការផ្ទាល់របស់ប្រធាន **គ.ស.ឌ.**
- សម្របសម្រួលការងារសន្តិសុខឌីជីថល រួមមាន អង្គភាពសន្តិសុខសាយប័រកម្ពុជា អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ អង្គភាពការពារជាតិក្នុងលំហសាយប័រ និងអង្គភាពការទូតសាយប័រ ជូន **គ.ស.ឌ.**
- គ្រប់គ្រងនិងគាំទ្រការងាររដ្ឋបាលទូទៅនៃ **គ.ស.ឌ.**
- គ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃ **គ.ស.ឌ.**
- រៀបចំ គ្រប់គ្រង និងប្រើប្រាស់ថវិការបស់ **គ.ស.ឌ.**
- គ្រប់គ្រងនិងរក្សាទុកឯកសារនិងទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- រៀបចំនិងបូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូន **គ.ស.ឌ.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ស.ឌ.**។

**មាត្រា៩ .-**

អង្គភាពសន្តិសុខសាយប័រកម្ពុជាស្ថិតក្រោមសមត្ថកិច្ចរបស់ **ក.ប.ឌ.** ត្រូវបំពេញមុខងារជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** លើកិច្ចការសន្តិសុខសាយប័រ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសន្តិសុខសាយប័រកម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យដោយឡែកតាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ឌ.**។

**មាត្រា១០ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការស្រាវជ្រាវ ស៊ើបអង្កេត បង្ក្រាបលើបទល្មើសបច្ចេកវិទ្យា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ដែលជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.**។ អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១១ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការការពារជាតិក្នុងលំហសាយប័រ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពការពារជាតិក្នុងលំហសាយប័រ ដែលជាសេនាធិការ

របស់អគ្គលេខាធិការដ្ឋាន **គ.ស.ឱ.**។ អង្គភាពការពារជាតិក្នុងលំហសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ច ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១២ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការការទូតសាយប័រ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពការទូតសាយប័រ ដែលជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឱ.**។ អង្គភាពការទូតសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១៣ .-**

លេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.ស.ឱ.** មានឋានៈស្មើនាយកដ្ឋាន ត្រូវដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួនជាជំនួយការដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.** និងជាអគ្គលេខាធិការ **គ.ស.ឱ.**។

**មាត្រា១៤ .-**

**គ.ស.ឱ.** មានត្រាដោយឡែក ដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **គ.ស.ឱ.** មានសិទ្ធិប្រើត្រារបស់ **គ.ស.ឱ.** សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ស.ឱ.

**មាត្រា១៥ .-**

ការចំណាយសម្រាប់ដំណើរការការងាររបស់ **គ.ស.ឱ.** និងលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.ស.ឱ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ **ក.ប.ទ.**។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពសន្តិសុខសាយប័រកម្ពុជា ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ **ក.ប.ទ.**។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពការពារជាតិក្នុងលំហសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពការទូតសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**គ.ស.ឱ.** មានសិទ្ធិទទួល គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងថវិកាដៃគូអភិវឌ្ឍ ព្រមទាំងធនធាន ជាថវិកា និងទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៤...... អនក្រ.បក ចុះថ្ងៃទី......១........ ខែ..មីនា...ឆ្នាំ២០២៤

ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសន្តិសុខឌីជីថល**



**មាត្រា១៦ ._**

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូន អនុប្រធានប្រចាំការ អនុប្រធាន និង សមាជិកនៃ **គ.ស.ឧ.** ត្រូវសម្រេចជាគោលការណ៍ដោយប្រមុខរាជរដ្ឋាភិបាល តាមសំណើរបស់អគ្គលេខាធិការនៃ **គ.ស.ឧ.**។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ស.ឧ.** ត្រូវសម្រេចដោយអគ្គលេខាធិការនៃ **គ.ស.ឧ.**។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៦ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ